ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១១៧០ អយក.ប្រក

# ប្រកាស
## ស្ដីពី
## ការប្ដូរឈ្មោះ និងប្ដូរគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន «សាលាភាពជាអ្នកដឹកនាំឡៃហ្គី» ទៅជា «សាលា អេយូធីភី ឡៃហ្គី លីឌឺហ្សីប អាកាឌឺមី»

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ ស្ដីពីការបើកសាលារៀនចំណេះទូទៅឯកជន
- បានឃើញប្រកាសលេខ៣៦២ អយក.ប្រក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការបើកសាលារៀនចំណេះទូទៅឯកជន
- បានពិនិត្យលិខិតស្នើសុំរបស់លោក **ដូមិនិក ហ្សាប** ជានាយកគ្រឹះស្ថានសិក្សា ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋមសិក្សា និងនាយដ្ឋានមធ្យមសិក្សាចំណេះទូទៅ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**សម្រេច**

**ប្រការ១ .-**

ត្រូវបានអនុញ្ញាតឱ្យ «**សាលា ភាពជាអ្នកដឹកនាំ ឡៃហ្គី**» កម្រិតបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ អនុវត្តកម្មវិធីសិក្សាអន្តរជាតិ ទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា តាមរយៈប្រកាសលេខ១៨៤ អយក.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅផ្លូវលេខ១១២ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្តូរឈ្មោះទៅជា «**សាលា អេឃូតីគី ឡៃហ្គី លីឌឺហ្ស៊ីប អាកាឌីមី**» និងអនុញ្ញាតឱ្យប្តូរគណៈគ្រប់គ្រងពីលោក «**ដូមិនិក ហ្សាប**» ទៅលោកស្រី «**សុខ លី**» ចាប់ពីឆ្នាំសិក្សា២០២៤-២០២៥ នេះតទៅ។

**ប្រការ២ .-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន «**សាលា អេឃូតីគី ឡៃហ្គី លីឌឺហ្ស៊ីប អាកាឌីមី**» ត្រូវដាក់បញ្ចូលកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរជាមុខវិជ្ជាកាតព្វកិច្ច ដោយកំណត់ម៉ោងសិក្សាស្របតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន «**សាលា អេឃូតីគី ឡៃហ្គី លីឌឺហ្ស៊ីប អាកាឌីមី**» ត្រូវពង្រឹងនិងលើកកម្ពស់ការសិក្សាវប្បធម៌និងអរិយធម៌ខ្មែរស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៣ .-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន «**សាលា អេឃូតីគី ឡៃហ្គី លីឌឺហ្ស៊ីប អាកាឌីមី**» ត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៤ .-**

លោកស្រី **សុខ លី** ជានាយិកាគ្រឹះស្ថានសិក្សាត្រូវដឹកនាំនិងគ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវៈ

- ចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាព និងគុណសម្បត្តិច្បាស់លាស់
- ជ្រើសរើសសិស្សឱ្យចូលរៀនដោយមិនមានការរើសអើង ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធានាដំណើរការបង្រៀន និងរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព
- គោរព និងអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងអប់រំ យុវជន និងកីឡា
- ធានាសណ្តាប់ធ្នាប់សង្គម និងធានាសុវត្ថិភាពផ្លូវកាយនិងផ្លូវចិត្តចំពោះសិស្សគ្រប់រូប
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ផ្នែករដ្ឋបាល និងបច្ចេកទេសជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡាតាមការកំណត់។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអប់រំកុមារតូច

ប្រធាននាយកដ្ឋានបឋមសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានកិច្ចការប្រឡង ប្រធាននាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ ប្រធានអង្គភាពពាក់ព័ន្ធ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងនាយក «**សាលា អេឃូភីភី ឡៃហ្គើ លីឌឺហ្សិប អាកាឌីមី**» មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានីភ្នំពេញ

*« ដើម្បីជូនជ្រាបជាព័ត៌មាន »*

- ដូចប្រការ៦ *« ដើម្បីអនុវត្ត »*
- កាលប្បវត្តិ-ឯកសារច្រកចេញចូលតែមួយ ក្រសួងអប់រំ យុវជន និងកីឡា